ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ១៤៦/០៨ — អាយលែន គ្លូរី**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **សេង រ៉ូចហ៊ុន**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **លី សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន អាយលែន គ្លូរី អ៊ិនដាសស្ទ្រៀល**
អាសយដ្ឋាន : ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០១២ ៤៣៤ ១៦៨ ទូរសារលេខ : គ្មាន
តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក JAY CHOO | ប្រធានក្រុមហ៊ុន |
| ២- លោក សុខ ចាន់ថា | ទីប្រឹក្សាក្រុមហ៊ុន |
| ៣- លោក នៅ ប៊ុនឃាង | ប្រធានរដ្ឋបាល |
| ៤- លោក ជា សារឿន | ប្រធានក្រុមសន្តិសុខ G.R.D |



មជ្ឈមណ្ឌលភ្នំពេញ អគារ A បន្ទប់លេខ ៣៣១ វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ : ០២៣ ២២០ ៧៩៣
Phnom Penh Center (A), Room 331, Sothearos Blvd, Sangkat Tonle Basak, Khan Chamkar Morn, Phom Penh · Tel/Fax: 023 220 793
Email: secretariat@arbitrationcouncil.org· Website: www.arbitrationcouncil.org

២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សហព័ន្ធសហជីព-សហជីពឃុំទជនខ្មែរ ម្ចាស់ទាំរោងចក្រ អោយលែន គ្លូរី**

អាសយដ្ឋាន : ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១៧ ៤៣០ ៣១២ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត : **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតទាមទារ ឱ្យក្រុមហ៊ុនផ្លាស់ប្តូរកិច្ចសន្យាការងារ ដែលមានកំណត់ថិរវេលាមានរយៈពេល៣ខែ ទៅជាកិច្ចសន្យាការងារដែលមានថិរវេលាកំណត់មានរយៈពេល ៦ ខែវិញ។ ដោយឡែក ភាគីក្រុមហ៊ុន សុំអនុវត្តតាមច្បាប់ស្តីពីការងារ ពោលគឺអនុវត្តតាមគោលការណ៍ចាស់។

២- កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុន ទទួលយកលោក សាត ប៊ុនធឿន ឱ្យចូលធ្វើការវិញជាធម្មតា ព្រមទាំងរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់រហូតដល់ថ្ងៃចូលធ្វើការវិញ។ ដោយឡែក ភាគីក្រុមហ៊ុនមិនអាចទទួលយកលោក សាត ប៊ុនធឿន ឱ្យចូលធ្វើការវិញបានឡើយ ហើយប្រាក់ឈ្នួល និងប្រាក់រង្វាន់ក៏មិនអាចរក្សាជូនបានទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១២៨៦ ក.ប/អក/វ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨។

**សវនាការ និង សន្និបាតពិគ្រោះមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨ វេលាម៉ោង ១៤:៣០ នាទី រសៀល ( ភាគីសហជីព និង កម្មករនិយោជិត អវត្តមាន) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងតាមទូរស័ព្ទរបស់កម្មករនិយោជិតប្រចាំក្រុមហ៊ុន ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាចុងក្រោយនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០២ ចំណុចលើការទាមទារចំនួន ០៣ចំណុច ។ ចំណុចមិនសះជាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨ វេលាម៉ោង ១៤:៣០ នាទីល្ងាច ប៉ុន្តែភាគីសហជីពកម្មករនិយោជិតមិនបានមកចូលរួមសវនាការ ហើយក៏មិនបានស្នើសុំជាលាយល័ក្ខណ៍អក្សរ ដើម្បីពន្យារពេលសវនាការ ដោយមានបញ្ជាក់ពីមូលហេតុត្រឹមត្រូវឱ្យបានមុនពេលសវនាការឡើយ ។ ដល់ម៉ោងបើកសវនាការ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទទៅភាគីសហជីព ភាគីសហជីពបានបង្ហាញឆន្ទៈក្នុងការលើកសវនាការដែរ តែនៅពេលដែលមន្ត្រីលេខាធិការក្រុមប្រឹក្សាអាជ្ញាកណ្តាលណែនាំឱ្យមកដាក់ពាក្យសុំតាមនីតិវិធី ភាគីសហជីពបានបោះបង់ឱកាសដោយមិនបានធ្វើតាមការណែនាំឡើយ ។ ចំណែកឯភាគីនិយោជកវិញ បានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអនុវត្តតាមច្បាប់ ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចលើចំណុចវិវាទ ក្នុងសំណុំរឿងនេះដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី :** គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក-ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន អាយលែន គ្លូរី ជូនលោក សុខ ចាន់ថា មុខងារទីប្រឹក្សាក្រុមហ៊ុន និងលោក នៅ ប៊ុនឃាង មុខងារប្រធានរដ្ឋបាលក្រុមហ៊ុន ដើម្បីចូលរួមដោះស្រាយវិវាទការងាររួម ក្រុមហ៊ុន អាយលែន គ្លូរី និងមានសិទ្ធិក្នុងការសម្រេចនៅពេលដោះស្រាយវិវាទ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៨។

២- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម នៃក្រុមហ៊ុន អាយលែន គ្លូរី លេខ ៨១៩ ពណ. នតក ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០០៥។

៣- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អាយលែន គ្លូរី ចុះបញ្ជិកាលេខ ០៨១ ក.ក.ប.វ/អក ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ២០០៥។

៤- លក្ខន្តិកៈក្រុមហ៊ុន អាយលែន គ្លូរី ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥។

៥- សេចក្តីជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហជីពយុវជនខ្មែរនៃក្រុមហ៊ុន អាយលែនគ្លូរី ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ។

៦- លិខិតស្តីពីកម្មករក្រុមហ៊ុនរោងចក្រផ្នែកជាងភ្លើងផ្លោះរបងចេញទៅក្រៅក្នុងម៉ោងធ្វើការ ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៨ ។

៧- លិខិតជូនដំណឹងស្តីពីការសុំធ្វើកូដកម្ម-បាតុកម្មអហិង្សា ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុនអាយលែន គ្លូរី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨

៩- តារាងបើកប្រាក់បៀវត្ស ៥% ប្រចាំខែកក្កដា ឆ្នាំ២០០៧ ។

១០- តារាងសងថ្លៃសំបុត្រពេទ្យប្រចាំខែ១២ ឆ្នាំ២០០៧-ខែ០៥ ឆ្នាំ២០០៨ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អាយលែន គ្លូរី លេខ ១២៨៦ ក.ប/ អក/វ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៨។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមក្រុមហ៊ុន អាយលែន គ្លូរី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៧២៥ កប/អក/លកអ. ចុះថ្ងៃទី២៨ ខែ វិច្ឆិកា ឆ្នាំ២០០៨។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៧២៤ កប/អក/លកអ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៨។

## អង្គហេតុ

- គ្មាន

## ហេតុផលនៃសេចក្ដីសម្រេច

នៅក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានចូលរួមសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដោយមិនបានបញ្ជាក់ពីមូលហេតុដែលមិនមកចូលរួមសវនាការ ទោះបីជាភាគីកម្មករនិយោជិត ទទួលបានការអញ្ជើញត្រឹមត្រូវ ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏ដោយ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោម:

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា "*ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្ដាល ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញសេចក្ដីបង្គាប់ ។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្ដាល ត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្ដាល មុនពេលធ្វើសេចក្ដីសម្រេចរបស់ខ្លួន*" ។

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ប្រការ ២១ ចែងថា "*ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេល ដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញសេចក្ដីបង្គាប់*" ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី លេខ ២៧/០៧-អ៊ឹម និង វ៉ៃ ៣ លេខ ៩៥/០៨-យ៉ុង វ៉ា ទី១ លេខ ១៣២/០៨-ជី អេច ជី និងលេខ ១៣៨/០៨-ម៉ាលីន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាល សម្រេចបិទសំណុំរឿងបាន "*លក្ខខណ្ឌទី១ : ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ : ភាគីមិនបានផ្ដល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន*" ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្ដាល ក្នុងសំណុំរឿងមុនៗ ខាងលើដែរ ។ ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ : ភាគីត្រូវបានជូនដំណឹងត្រឹមត្រូវ**

ដោយផ្អែកលើចំណុច (ឃ) ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីកម្មករនិយោជិត ឱ្យមកយកលិខិតអញ្ជើញចូលរួមសវនាការ ប៉ុន្តែភាគីកម្មករនិយោជិត មិនបានមកយកលិខិតអញ្ជើញនេះដោយផ្ទាល់ទេ ហើយមកដល់ពេលសវនាការ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានទូរស័ព្ទរំលឹកដល់ភាគីកម្មករនិយោជិត ដើម្បីមកចូលរួមសវនាការឱ្យទាន់តាមពេលវេលាកំណត់ដែរ ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានឆ្លើយថា មិនអាចមកចូលរួមសវនាការបានទេ ទោះបីជាទទួលបានដំណឹងអំពីកាលបរិច្ឆេទសវនាការ ពេលវេលា និងទីកន្លែងសវនាការរួចហើយ ស្របតាមវិធាន ៤.៧ ដែលជាឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ដោយ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិត ពិតជាបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសវនាការប្រាកដមែន ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ **ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ ។**

**លក្ខខណ្ឌទី ២ : ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "ពាក្យបង្ហាញខ្លួនក្នុងសវនាការ" ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់ ។

ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី ។

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីសហជីព និងកម្មករនិយោជិត មិនបានបង្ហាញខ្លួននៅក្នុងសវនាការតាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ២១ ខាងលើនេះទេ ។ **ហេតុនេះហើយ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ។**

**លក្ខខណ្ឌទី ៣ : ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ក្នុងករណីនេះ ភាគីសហជីព និងកម្មករនិយោជិត មិនបានផ្តល់ហេតុផលណាមួយសម្រាប់ការមិនចូលរួមសវនាការនេះទេ ពីព្រោះមកដល់ថ្ងៃសវនាការ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៨ វេលាម៉ោង ១៤:៣០ នាទីល្ងាច លេខា



Mhea

ធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើទំនាក់ទំនងតាមទូរស័ព្ទរំលឹកទៅភាគីនិយោជក និងភាគីសហជីព កម្មករនិយោជិត ស្រាប់តែភាគីសហជីព កម្មករនិយោជិតបានឆ្លើយថា ជាប់រវល់មិនអាចមកចូលរួមសវនាការបានទេ។ មន្ត្រីលេខាធិការដ្ឋាន បានសួរបញ្ជាក់បន្ថែមទៀតថា តើអាចឱ្យតំណាងកម្មករនិយោជិត ថ្នាក់ដឹកនាំសហជីពផ្សេងទៀតមកចូលរួមសវនាការបានទេ។ ប៉ុន្តែ ភាគីសហជីព កម្មករនិយោជិតបានបញ្ជាក់ថា មិនអាចមកចូលរួមសវនាការនេះបានឡើយ។ ហើយពេលនោះ ភាគីសហជីពបានបង្ហាញឆន្ទៈក្នុងការលើកសវនាការដែរ នៅពេលដែលមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានណែនាំឱ្យភាគីសហជីព មកដាក់ពាក្យសុំពន្យារសវនាការតាមនីតិវិធី។ ប៉ុន្តែ ភាគីសហជីពបានបោះបង់ឱកាស ដោយមិនបានមកដាក់ពាក្យសុំពន្យារសវនាការតាមការណែនាំឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលកត់សំគាល់ឃើញថា បើភាគីសហជីព កម្មករនិយោជិត មានបំណងចង់លើកពេលសវនាការនោះ គួរគប្បីធ្វើពាក្យស្នើសុំជាលាយល័ក្ខណ៍អក្សរ ដោយផ្ដល់មូលហេតុសមស្រប មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឱ្យបានមុនថ្ងៃសវនាការ។ ម្យ៉ាងទៀត ចំពោះពេលវេលាសវនាការ បើភាគីសហជីព កម្មករនិយោជិត បានទទួលដំណឹងរួចហើយ ក៏មិនគប្បីឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលជាអ្នករំលឹកអំពីពេលវេលាសវនាការនោះឡើយ។ ចំណែកឯភាគីក្រុមហ៊ុន បានអញ្ជើញមកចូលរួមក្នុងសវនាការ តាមកាលកំណត់ និងបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្ដាលអនុវត្តតាមច្បាប់។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា **ភាគីសហជីព កម្មករនិយោជិត មិនបានផ្ដល់មូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួននេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។**

ជាសរុបមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ទោះបីភាគីសហជីព កម្មករនិយោជិត មិនចូលរួមក្នុងដំណើរការអាជ្ញាកណ្ដាល ក៏ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានអំណាចក្នុងការចេញសេចក្ដីបង្គាប់ដែរ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានផ្ដល់ឱកាសគ្រប់គ្រាន់ដល់សហជីពយុវជនខ្មែរ ប្រចាំរោងចក្រ អាយលែន គ្លូរី ដែលជាភាគីដើមបណ្ដឹង ក្នុងការធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិត ដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្ដីពីការងារ។ ប៉ុន្តែសហជីពយុវជនខ្មែរ ប្រចាំរោងចក្របានជ្រើសរើសការមិនចូលរួមសវនាការ និងបោះបង់ឱកាសក្នុងការបង្ហាញភស្តុតាង ដើម្បីគាំទ្រការទាមទាររបស់ខ្លួនទៅវិញ។ ជាទូទៅ ដើមបណ្ដឹងមានកាតព្វកិច្ចផ្ដល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីការពារបណ្ដឹងរបស់ខ្លួន។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ ភាគីសហជីព និងកម្មករនិយោជិត ដែលជាភាគីដើមបណ្ដឹងមិនបានផ្ដល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្ដឹងរបស់ខ្លួនទេ។ ក្នុងករណី ភាគីដើមបណ្ដឹងមិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្ដល់ហេតុផល និងភស្តុតាង

ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈ ដោយសុទ្ធចិត្តរបស់ភាគីសហជីព កម្មករនិយោជិតក្នុងការយកវិវាទការងាររបស់ខ្លួន មកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បិទសំណុំរឿងលេខ ១៨៦/០៨-អាយលែន គ្លូរី នេះ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅនេះ:

## សម្រេច និង បង្គាប់

- សម្រេចបិទសំណុំរឿងលេខ ១៨៦/០៨-អាយលែន គ្លូរី ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **សេង ឡុងហ៊ុន**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈារ**

ហត្ថលេខា: ------------------------------